**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ៣៩៨ /២០ **ក.ប/**ប្រ.ក.ស.ក

ការិយាល័យរដ្ឋបាល ក.វ.ប.វ
លេខ: ១៣៣/២០
ថ្ងៃទី ១៦ ខែ ៤ ឆ្នាំ២០២០

# ប្រកាស
# ស្តីពី
# ការកែសម្រួលសមាសភាពលេខាធិការដ្ឋានរបស់ ក្រុមការងារទេសន្តរប្រវេសន៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង ក្រុមការងារអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៤៥ សសរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចលេខ ០៩៨/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នសម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

- បានឃើញសេចក្ដីសម្រេចលេខ ០៧០/១៥ សសរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងសមាសភាពក្រុមការងារទេសន្តរប្រវេសន៍
- បានឃើញប្រកាសលេខ ២០៤ កប/ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការបង្កើតលេខាធិការដ្ឋានសម្រាប់ក្រុមការងារទេសន្តរប្រវេសន៍ការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះ ដោយសារការជួញដូរ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ ._**

ត្រូវបានការកែសម្រួលសមាសភាពលេខាធិការដ្ឋានរបស់ក្រុមការងារទេសន្តរប្រវេសន៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះ ដោយសារការជួញដូរ ដែលមានឈ្មោះដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ហេង សួរ** | រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ប្រធាន |
| ២. | ឯកឧត្តម **ហ៊ី ឌុន្នី** | រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. | ឯកឧត្តម **កែវ ចិសិដ្ឋ** | អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤. | ឯកឧត្តម ឧ.ឯក **ខៀវ ចាន់រ៉ា** | អគ្គលេខាធិការរង គ.ជ.ប.ជ | អនុប្រធាន |
| ៥. | ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦. | លោកជំទាវ **ឡុង សុផល្លី** | អនុរដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី | អនុប្រធាន |
| ៧. | ឯកឧត្តម **សោម ចំណាន** | អនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨. | លោកជំទាវ **សួស រដ្ឋាវី** | អនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៩. | ឯកឧត្តម **ជុំ កុសល** | រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន | សមាជិក |
| ១០. | ឯកឧត្តម **ខុយ រិទ្ធ** | អនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១១. | ឯកឧត្តម **សេង សក្កដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |

| | | | |
|---|---|---|---|
| ១២. ឯកឧត្តម **ហាំង តុលា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣. ឯកឧត្តម **ស៊ុំ សោភ័ណ** | ទីប្រឹក្សាអមក្រសួង និង<br>ជានាយករងបេឡាជាតិសន្តិសុខសង្គម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤. ឯកឧត្តម **ឡូ សុភារិទ្ធ** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាន<br>ទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥. ឯកឧត្តម **ឆាង ស៊ាងឆេង** | ទីប្រឹក្សាអមក្រសួង និង<br>ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦. លោកជំទាវ ឧ.ឯក **ឌុច ដាណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម<br>នៃក្រសួងមហាផ្ទៃ | សមាជិកា |
| ១៧. ឯកឧត្តម ឧ.ឯក **ចុង សុវណ្ណនី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. លោក **ជួប ណារ៉ាត់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩. លោក **ហួន សុខភានាថ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២០. លោកស្រី **យឹម ពេជ្រម៉ាលីកា** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន<br>អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ២១. លោកស្រី **ទ្រាំ សុខន** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស<br>និងសមាហរណកម្មជនរងគ្រោះ នៃក្រសួង<br>សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ២២. លោក **ទៀវ និត្យាកោមល** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣. លោក **តុន សុភ័ក្ត** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៤. លោក **ថូ ម៉ិនថន** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៥. លោក **អ៊ុក រ៉ាឌុធ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

| | | | | |
|---|---|---|---|---|
| ២៦. លោក | **ទូច** | **ពណ្ណរាយ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៧. លោក | **គន់** | **សម្បត្តិ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៨. លោក | **យឹម** | **សុសំរេច** | ប្រធានការិ. នៃនាយកដ្ឋានមុខរបរនិងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៩. លោកជំទាវឧកញ៉ា | **អ៊ុខ** | **ស៊ាខរិទ្ធី** | ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា | សមាជិកា |
| ៣០. លោក | **អន** | **ម៉ិនហាក់** | ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា | សមាជិក |
| ៣១. លោក | **ម៉ន** | **មិត** | មន្ត្រីសម្របសម្រួលអង្គការអន្តរជាតិខាងការងារ | សមាជិក |
| ៣២. លោក | **អ៊ុយ** | **អត្ថរា** | មន្ត្រីគម្រោងថ្នាក់ជាតិអង្គការអន្តរជាតិទេសន្តរប្រវេសន៍ | សមាជិក |
| ៣៣. លោក | **ឃុន** | **សុតា** | អ្នកវិភាគកម្មវិធី និងជាតំណាងUN-WOMEN Cambodia Office | សមាជិក |
| ៣៤. លោក | **ម៉ុំ** | **សុខចារ** | នាយកអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី | សមាជិក |
| ៣៥. លោក | **គីម** | **ចាន់សំណាង** | ប្រធានសហភាពសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន | សមាជិក |
| ៣៦. លោក | **នាក់** | **ហោច** | ប្រធានសមាគមដឹកជញ្ជូន និងការងារក្រៅប្រព័ន្ធស.ជ.ក.ប | សមាជិក |
| ៣៧. លោក | **ខួន** | **សទ្ធី** | មន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៣៨. លោក | **ឈាន** | **សារៈបញ្ញា** | មន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

**ប្រការ២ ._**

លេខាធិការដ្ឋាននេះមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលរាល់ការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទាក់ទងភារកិច្ចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួយដូរមនុស្ស (គ.ជ.ប.ជ) និងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ
- សម្របសម្រួល រាល់ការងាររបស់ប្រធានក្រុមការងារទេសន្តរប្រវេសន៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួយដូរមនុស្ស (គ.ជ.ប.ជ)
- រៀបចំកិច្ចប្រជុំនានារបស់ក្រុមការងារទេសន្តរប្រវេសន៍
- ប្រមូល និងចងក្រងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីលទ្ធផលនៃការអនុវត្តការងារទាក់ទងនឹងទេសន្តរប្រវេសន៍ការងាររបស់ក្រសួង ស្ថាប័នជាសមាជិកក្រុមការងារទេសន្តរប្រវេសន៍ ដើម្បីបូកសរុបរបាយការណ៍ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗទៀតនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អង្គភាពពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងភាគីថៃ ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ
- លេខាធិការដ្ឋានមានរបបប្រជុំសាមញ្ញ ១ខែ ១ដងៗ ប្រធានលេខាធិការដ្ឋាន អាចកោះប្រជុំវិសាមញ្ញ និងអាចអញ្ជើញអង្គភាពពាក់ព័ន្ធចូលរួមប្រជុំ ក្នុងករណីចាំបាច់
- រៀបចំគម្រោងថវិកា សម្រាប់ដំណើរការរបស់ក្រុមការងារទេសន្តរប្រវេសន៍ និងលេខាធិការដ្ឋាន
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានក្រុមការងារទេសន្តរប្រវេសន៍ប្រគល់ជូនៗ

**ប្រការ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ៗ

**ប្រការ៤ .–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅៗ

ថ្ងៃ ចន្ទ ៧រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ